# ពាង្រាងសំណើគម្រោងបទបញ្ញត្តិនីតិវិធី
# ដែលរៀបរាងដោយបុគ្គលិក

## I. សេចក្តីផ្តើម

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 (ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239) តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងឋបបនីយភណ្ឌថាមពលអគ្គិសនី (“ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង” ឬ “EFSB”) ប្រកាសឱ្យប្រើបទបញ្ញត្តិដើម្បីអនុវត្តការផ្លាស់ប្តូរចំពោះច្បាប់ទូទៅ ជំពូក 164 ផ្នែក 69G ដល់ 69J¼ ផ្នែក 69O និង 69P ផ្នែក 69R និង 69S និងផ្នែក §§ 69T ដល់ 69W។ ដូចបានកែប្រែ ផ្នែកទាំងនេះអនុញ្ញាតឱ្យក្រុមប្រឹក្សាកំណត់ទីតាំងចេញលិខិតអនុញ្ញាតិរួមតែមួយគត់ដែលមានលិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានទាំងអស់ដែលទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតត្រូវការចាំបាច់ដើម្បីចាប់ផ្តើមសាងសង់ និងប្រតិបត្តិការ។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ប្រកាសឱ្យប្រើបទប្បញ្ញត្តិនេះមិនឱ្យលើសពីថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 ឡើយ ហើយបទប្បញ្ញត្តិនេះនឹងអនុវត្តចំពោះគម្រោងក្នុងដែន យុត្តាធិការទាំងអស់ដែលបានដាក់ជូនក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនៅថ្ងៃ និងក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026។ ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 132 ។

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងធ្វើការពិគ្រោះយោបល់ជាមួយភ្នាក់ងារផ្សេងៗនៅពេលរៀបចំបទប្បញ្ញត្តិ រួមទាំងនាយកដ្ឋានសេវាសាធារណៈ ("DPU") នាយកដ្ឋានធនធានថាមពល នាយកដ្ឋានការពារបរិស្ថាន នាយកដ្ឋានជលផលនិងល្បែងកម្សាន្ត នាយកដ្ឋានអភិរក្សនិងសកម្មភាពកម្សាន្ត នាយកដ្ឋានធនធានកសិកម្ម ការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាឈូសិត នាយកដ្ឋានដឹកជញ្ជូនរដ្ឋម៉ាសាឈូសិត និងការិយាល័យប្រតិបត្តិសុវត្ថិភាពនិងសន្តិសុខសាធារណៈ។ លើសពីនេះ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាកំណត់ទីតាំងធ្វើការពិគ្រោះយោបល់ជាមួយទីភ្នាក់ងារ អាជ្ញាធរ និងនាយកដ្ឋានផ្សេងទៀតទាំងអស់ ដែលចាំបាច់ត្រូវមានការយល់ព្រម បទបញ្ជា លក្ខខណ្ឌសេចក្តីបង្គាប់ លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬការអនុញ្ញាតរបស់ពួកគេជាទម្រង់ណាមួយមុនពេល ឬសម្រាប់ការសាងសង់កន្លែងទីតាំងមួយ ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច ឬទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ ដូចដែលបានកំណត់ដោយលក្ខន្តិកៈ។ ច្បាប់លក្ខន្តិកឆ្នាំ 2024 ជំពូក 239 ផ្នែក 132 ។

ពាង្រាងសំណើគម្រោងនេះបង្ហាញពីការផ្លាស់ប្តូរបទប្បញ្ញត្តិដែលតម្រូវឱ្យអនុវត្តច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ។ លើសពីនេះ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើឱ្យមានការកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់របស់ខ្លួន ដើម្បីលើកកម្ពស់ភាពច្បាស់លាស់និងប្រសិទ្ធភាពកាន់តែខ្ពស់នៅក្នុងដំណើរការនីតិវិធីរបស់យើង។

## II. ទិដ្ឋភាពទូទៅស្តីពីសមាសធាតុពាង្រាងសំណើគម្រោងសំខាន់ៗ

បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលគឺមាននៅក្នុងក្រមបទប្បញ្ញត្តិរដ្ឋម៉ាសាឈូសិត (CMR) មាត្រា 980 ផ្នែក 1.00 ដល់ 12.00 ។ នៅក្នុងសំណើនេះ បុគ្គលិកក្រុមប្រឹក្សាភិបាលស្នើឱ្យកែប្រែបទប្បញ្ញត្តិដែលមានស្រាប់ បង្កើតបទប្បញ្ញត្តិថ្មីសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត និងលុបចោលបទប្បញ្ញត្តិដែលផុតសុពលភាព។ នីតិវិធីរបស់ក្រុមប្រឹក្សាភិបាលក្នុងការពិនិត្យឡើងវិញនូវទីតាំងនានា ក្រោមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J និង 69J¼, ច្បាប់ទូទៅ ជំពូក 164

ផ្នែក 69K-69O½, ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T-69V, និងការកាត់សេចក្តីសាជាថ្មី[1] ដោយអភិបាលនៃក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអនុលោមតាមច្បាប់ទូទៅ ជំពូក164 ផ្នែក 69W គឺជានីតិវិធីកាត់សេចក្តី ដូច្នេះត្រូវស្ថិតនៅក្រោមច្បាប់នីតិវិធីរដ្ឋបាលរដ្ឋម៉ាសាឈូសិត ច្បាប់ទូទៅ ជំពូក 30A ។ ទាំងសេចក្តីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចស្ថាពររបស់អភិបាល អនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69W អាចត្រូវបានប្តឹងឧទ្ធរណ៍ដោយភាគីណាមួយទៅកាន់តុលាការកំពូលដែលមានយុត្តាធិការនៅរដ្ឋម៉ាសាឈូសិត។

បទប្បញ្ញត្តិនិតិវិធីបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង វិធានសម្រាប់ការប្រតិបត្តិនៃនីតិវិធីកាត់សេចក្តីគឺមាននៅក្នុងក្រម CMR មាត្រា 980 ផ្នែក 1.00 ។ វិធានរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងដែលគ្រប់គ្រងប្រតិបត្តិការរបស់ក្រុមប្រឹក្សាភិបាល ពត៌មានទូទៅ និងការប្រតិបត្តិអាជីវកម្មរបស់ក្រុមប្រឹក្សាភិបាល គឺមាននៅក្នុងក្រម CMR មាត្រា 980 ផ្នែក 2.00 ។ ពង្រាងសំណើគម្រោងនេះស្នើឱ្យមានការផ្លាស់ប្តូរសំខាន់ៗចំពោះសំណុំបទប្បញ្ញត្តិទាំងពីរ។

បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ក៏ស្នើបទប្បញ្ញត្តិថ្មីមួយចំនួនដើម្បីដោះស្រាយដំណើរការច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ថ្មីដែលទាក់ទងនឹងការអនុញ្ញាតរួមសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត៖

ក្រម CMR មាត្រា 980 ផ្នែក 13.00៖ លិខិតអនុញ្ញាតរួមសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។
ក្រម CMR ជំពូក 980 ផ្នែក 14.00៖ ការវិនិច្ឆ័យសាជាថ្មីលើការស្នើសុំលិខិត អនុញ្ញាតរួមថ្នាក់មូលដ្ឋាន
ក្រម CMR មាត្រា 980 ផ្នែក 15.00៖ ការវិភាគផលប៉ះពាល់រួម និងស្តង់ដាភាពសមស្របនៃទីតាំង
ក្រម CMR មាត្រា 980 ផ្នែក 16.00៖ ការពិគ្រោះយោបល់ជាមុន និងការចូលរួមរបស់សហគមន៍។

បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងកត់សំគាល់ថាស្តង់ដាវិភាគផលប៉ះពាល់រួម និងសំណើពិគ្រោះយោបល់និងការចូលរួមរបស់សហគមន៍មុនដាក់ពាក្យសុំ ត្រូវបានរៀបរាប់លម្អិតនៅក្នុងពង្រាងសំណើផ្សេងទៀតដែលបុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងចេញជូនសម្រាប់មតិយោបល់សាធារណៈ។ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងក៏កត់សម្គាល់ផងដែរថា ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន កំពុងរៀបចំដាច់ដោយឡែកពីគ្នានូវការណែនាំអំពីការវិភាគផលប៉ះពាល់រួម និងការណែនាំអំពីភាពសមស្របនៃទីតាំង ដែលនឹងជូនដំណឹងអំពីបទប្បញ្ញត្តិដែលបានស្នើឡើងរបស់ក្រុមប្រឹក្សាភិបាល។ បុគ្គលិកក្រុមប្រឹក្សាភិបាលមានបំណងចេញសេចក្តីណែនាំលម្អិតបំពេញបន្ថែមដើម្បីជួយអ្នកដាក់ពាក្យសុំនៅក្នុងការគោរពតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងក៏ស្នើឱ្យលុបចោលបទប្បញ្ញត្តិខាងក្រោមដែលលែងប្រើប្រាស់តទៅទៀត៖

ក្រម CMR មាត្រា 980 ផ្នែក 4.00៖ សេរីភាពនៃព័ត៌មាន ការការពារការសម្ងាត់ពាណិជ្ជកម្ម
ក្រម CMR មាត្រា 980 ផ្នែក 5.00៖ ការវាយតម្លៃបរិស្ថាន និងផលប៉ះពាល់បរិស្ថាន

---

1 ការកាត់សេចក្តីសាជាថ្មីគឺមានន័យថា អភិបាលនៃក្រុមប្រឹក្សាភិបាល នឹងធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាងនៅចំពោះមុខអភិបាល និងជាជាងផ្អែកលើឯកសារដែលមាននៅក្នុងការត្រួតពិនិត្យថ្នាក់ក្រុងទៅលើពាក្យសុំលិខិតអនុញ្ញាតនោះ។ ភាគីអាចស្នើសុំឱ្យក្រុមប្រឹក្សាភិបាល EFSB រួមបញ្ចូលកំណត់ត្រាពីនីតិវិធីពីមុនមករបស់ថ្នាក់រដ្ឋឬថ្នាក់មូលដ្ឋានទៅក្នុងកំណត់ត្រានោះនៅចំពោះមុខក្រុមប្រឹក្សាភិបាល EFSB ។

ក្រុម CMR មាត្រា 980 ផ្នែក 7.00៖ ការព្យាករណ៍រយៈពេលវែង និងការបំពេញបន្ថែម
ក្រុម CMR មាត្រា 980 ផ្នែក 8.00៖ សេចក្តីជូនដំណឹងអំពីបំណងក្នុងការសាងសង់ទីតាំងរោងចក្រប្រេង
ក្រុម CMR មាត្រា 980 ផ្នែក 9.00 ការជ្រើសរើស ការវាយតម្លៃ និងការប៉ាន់ប្រមាណ
ក្រុម CMR មាត្រា 980 ផ្នែក 11.00៖ ការផ្តល់អាជ្ញាបណ្ណទីតាំងរោងចក្រផលិតថាមពលវារីអគ្គិសនី

សម្រាប់គម្រោងដែលស្ថិតនៅក្រោមយុត្តាធិការរបស់នាយកដ្ឋាន DPU ផ្នែកកំណត់ទីតាំងអនុវត្តតាមបទប្បញ្ញត្តិនីតិវិធីរបស់នាយកដ្ឋាន DPU ដែលមាននៅក្រុម CMR មាត្រា 220 ផ្នែក 1.00 ។ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងកត់សំគាល់ថា បន្ទាប់ពីថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 យុត្តាធិការកំណត់ទីតាំងនិងអនុញ្ញាតរបស់នាយកដ្ឋាន DPU ទាំងអស់ត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ហើយនឹងស្ថិតនៅក្រោមបទប្បញ្ញត្តិដែលមាននៅក្រុម CMR មាត្រា 980 ។

នាយកដ្ឋាន DPU ក៏កំពុងបង្កើតបទប្បញ្ញត្តិដើម្បីអនុវត្តច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ផងដែរ។ បទប្បញ្ញត្តិទាំងនេះត្រូវបានពិពណ៌នានៅក្នុងពង្រាងសំណើគម្រោងផ្សេងទៀត ហើយត្រូវបានកត់សម្គាល់នៅទីនេះសម្រាប់ជាសេចក្តីយោង។

ក្រុម CMR មាត្រា 220 ផ្នែក XXX៖ ថ្លៃពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB
ក្រុម CMR មាត្រា 220 ផ្នែក XXX៖ ផ្នែកនៃការចូលរួមរបស់សាធារណជន
ក្រុម CMR មាត្រា 220 ផ្នែក XXX៖ កម្មវិធីមូលនិធិជំនួយអន្តរការី

## III. ការពិភាក្សាអំពីការផ្លាស់ប្តូរបទប្បញ្ញត្តិ

### A. ការកែប្រែបទប្បញ្ញត្តិដែលមានស្រាប់

បទប្បញ្ញត្តិនីតិវិធី ក្រុម CMR មាត្រា 980 ផ្នែក 1.00៖ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើឱ្យមានការផ្លាស់ជាច្រើនទៅលើក្រុម CMR មាត្រា ផ្នែក 1.00 ដើម្បីឆ្លុះបញ្ចាំងពីដំណើរការអនុញ្ញាតរួមបញ្ចូលថ្មីនេះ។ ផ្នែកនេះនឹងអនុវត្តចំពោះរាល់នីតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងទាំងអស់ក្រោមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69H-69W លើកលែងតែមានការកត់សម្គាល់ផ្សេងទៀតផ្ទុយពីនេះ។ ការផ្លាស់ប្តូរនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 សម្រាប់គម្រោងដែលបានដាក់នៅថ្ងៃ ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026។ ក្រុមប្រឹក្សាភិបាលនឹងធ្វើវិសោធនកម្មផ្នែកនិយមន័យនៅក្នុងបទប្បញ្ញត្តិដើម្បីឆ្លុះបញ្ចាំងពីនិយមន័យថ្មីនៅក្នុងច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំគម្រោងដាក់ញត្តិស្នើសុំសាងសង់ទីតាំងរោងចក្រ ញត្តិស្នើសុំវិញ្ញាបនបត្រស្តីពីផលប៉ះពាល់បរិស្ថាននិងផលប្រយោជន៍សាធារណៈ ពាក្យស្នើសុំលិខិតអនុញ្ញាតរួម ឬពាក្យស្នើសុំការវិនិច្ឆ័យសាជាថ្មី ជាទម្រង់ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលបានធ្វើបច្ចុប្បន្នភាពតាមដំណាក់កាល។ បទប្បញ្ញត្តិនឹងកំណត់លក្ខខណ្ឌតម្រូវការដាក់ឯកសារជាក់លាក់ និងយោងការណែនាំអំពីកម្មវិធីដែលបានបង្កើតថ្មីសម្រាប់ព័ត៌មានលម្អិតជាក់លាក់ ដើម្បីណែនាំអ្នកដាក់ពាក្យសុំឱ្យគោរពតាមបទប្បញ្ញត្តិ។ បទប្បញ្ញត្តិតម្រូវឱ្យអ្នកដាក់ពាក្យសុំអនុវត្តតាមលក្ខខណ្ឌតម្រូវការវិភាគផលប៉ះពាល់រួមនៃច្បាប់នេះ ដែលនឹងត្រូវបានរៀបរាប់លម្អិតនៅក្នុងបទប្បញ្ញត្តិនិងការណែនាំដាច់ដោយឡែក។ បទប្បញ្ញត្តិនីតិវិធីក៏នឹងតម្រូវឱ្យអ្នកដាក់ពាក្យសុំផ្តល់ភស្តុតាងជាមួយនឹងការដាក់ពាក្យស្នើសុំរបស់ពួកគេដែលបញ្ជាក់ថា ពួកគេបានបញ្ចប់ការពិគ្រោះយោបល់មុនដាក់ពាក្យសុំ និងសកម្មភាពចូលរួមសហគមន៍ មុនពេលដាក់ញត្តិ ឬពាក្យសុំទៅកាន់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង។ បណ្តុំនៃបទប្បញ្ញត្តិដាច់ដោយឡែកនឹងកំណត់លក្ខខណ្ឌតម្រូវទាំងនេះ។ បទប្បញ្ញត្តិដែលបានស្នើឡើងនឹងឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិជាឯកតោភាគីដែលហាមឃាត់ផ្នែកចូលរួមជាសាធារណៈរបស់

នាយកដ្ឋាន DPU ដែលត្រួតពិនិត្យសកម្មភាពមុនដាក់ពាក្យសុំរបស់អ្នកដាក់ពាក្យសុំ មិនឱ្យចូលរួមក្នុងដំណើរការវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង។[2]

បុគ្គលិកក្រុមប្រឹក្សាកំណត់ទីតាំងក៏ស្នើឱ្យធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិនីតិវិធីរបស់ខ្លួនផងដែរ ដើម្បីទាមទារឱ្យដាក់សំណើតាមប្រព័ន្ធអេឡិចត្រូនិក និងតម្រូវឱ្យដាក់សំណើទាំងនោះជាទម្រង់ដែលអាចស្វែងរកបាន។ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើឱ្យរួមបញ្ចូលនៅក្នុងបទប្បញ្ញត្តិនោះនូវការអនុវត្តការជូនដំណឹងតាមប្រៃសណីយ៍ដែលមានស្រាប់របស់ខ្លួន រួមទាំងការតម្រូវឱ្យមានការជូនដំណឹងតាមប្រៃសណីយ៍សម្រាប់រយៈចម្ងាយដូចខាងក្រោមចាប់ពីព្រំប្រទល់ដែនគម្រោង (ដូចជាព្រំប្រទល់ផ្លូវដែលអាចចេញចូលបាន)៖

(a) ចម្ងាយ 300 ហ្វីតពីព្រំប្រទល់ផ្លូវដែលអាចចេញចូលបានសម្រាប់គម្រោងខ្សែត្រង់ ឬជាគុជ្ឈ័គម្រោងខ្សែត្រង់ ដូចជាខ្សែបញ្ជូនចរន្ត និងបំពង់បង្ហូរឧស្ម័នជាដើម។
(b) ចម្ងាយមួយភាគបួនម៉ាយពីខ្សែបន្ទាត់អចលនទ្រព្យសម្រាប់គម្រោង និងជាគុជ្ឈ័នៃគម្រោងសម្រាប់ស្ថានីយ៍ផ្លាស់ប្ដូរចរន្តអគ្គិសនី អនុស្ថានីយ ស្ថានីយ៍វាស់បរិមាណឧស្ម័ន និងឧបករណ៍គ្រប់គ្រងសម្ពាធឧស្ម័ន និង
(c) ចម្ងាយកន្លះម៉ាយពីខ្សែបន្ទាត់អចលនទ្រព្យសម្រាប់ទីតាំងរោងចក្រ ផលិតអគ្គិសនី ទីតាំងស្តុកឧស្ម័ន ប្រព័ន្ធស្តុកថាមពល និងស្ថានីយបំលែនហ្គាស។

បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើឱ្យបង្ហាញថាបុគ្គល ឬអង្គភាពណាមួយអាចដាក់ញត្តិសុំអន្តរាគមន៍ ហើយមិនតម្រូវឱ្យមានមេធាវីតំណាងដោយអាណត្តិណាម្នាក់ឡើយ លើកលែងតែសាជីវកម្មដែលត្រូវតែមានមេធាវីតំណាងដោយអាណត្តិ។ វិធានអន្តរាគមន៍បន្ថែមដែលអនុវត្តចំពោះហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតត្រូវបានយោងនៅក្នុងក្រម CMR មាត្រា 980 ផ្នែក 13.00 ។

លើសពីនេះ បទប្បញ្ញត្តិនឹងតម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបន្តធ្វើសវនាការស្តាប់មតិសាធារណៈរបស់ខ្លួនដោយផ្ទាល់និងតាមអនឡាញ ដរាបណាសវនាការនេះនៅតែអាចអនុវត្តបាន។ លើសពីនេះ បទប្បញ្ញត្តិដែលបានស្នើឡើងនឹងផ្តល់សិទ្ធិដល់មន្ត្រីវិនិច្ឆ័យសេចក្តីឱ្យអនុវត្តដំណើរការសវនាការលើភស្តុតាងតាមអនឡាញ។

បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងតម្រូវឱ្យក្រុមប្រឹក្សាភិបាលផ្តល់នូវលទ្ធភាពប្រើប្រាស់ភាសាស្របតាមផែនការប្រើប្រាស់ភាសាបច្ចុប្បន្នរបស់ខ្លួន។

បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើសុំបទប្បញ្ញត្តិដែលនឹងរួមបញ្ចូលបទប្បញ្ញត្តិជាច្រើនដែលបច្ចុប្បន្នត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធានមូលដ្ឋាននីតិវិធីដែលមន្ត្រីវិនិច្ឆ័យសេចក្តីចេញទៅឱ្យភាគីនានានៅពេលចាប់ផ្តើមនីតិវិធីនីមួយៗ។ បទប្បញ្ញត្តិនឹងតម្រូវឱ្យមានការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារដែលបានដាក់ជូនក្រុមប្រឹក្សាភិបាលក្នុងដំណើរការនីតិវិធី និងទទួល

[2] បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលហាមប្រាមភាគីម្ខាងមិនឱ្យទំនាក់ទំនងប្រាប់ដល់អ្នកធ្វើសេចក្តីសម្រេចឬបុគ្គលិកអំពីអង្គសេចក្តីនៃនីតិវិធីវិនិច្ឆ័យ ដោយមិនអនុញ្ញាតឱ្យភាគីផ្សេងទៀតទាំងអស់ចូលរួមទៅក្នុងការទំនាក់ទំនងនោះ។ ក្រម CMR មាត្រា 980 ផ្នែក 1.03(8) (ចាប់ពីការដាក់សំណើដំណាក់កាលដំបូងក្នុងនីតិវិធីវិនិច្ឆ័យសេចក្តីរហូតដល់ការចេញសេចក្តីសម្រេចស្ថាពរ គ្មានភាគីណាមួយ ឬអ្នកចូលរួមក្នុងដែនកំណត់សិទ្ធិណាម្នាក់ អាចទំនាក់ទំនងប្រាប់ជាលក្ខណៈឯកជនទាក់ទងនឹងបញ្ហាសំខាន់ៗនៃនីតិវិធីនេះទៅដល់មន្ត្រីវិនិច្ឆ័យសេចក្តី សមាជិកក្រុមប្រឹក្សាភិបាលណាមួយ ឬបុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងពាក់ព័ន្ធនឹងនីតិវិធីការវិនិច្ឆ័យសេចក្តីនេះទេ)។

ស្គាល់កាតព្វកិច្ចបន្តរបស់ភាគីដើម្បីធ្វើបច្ចុប្បន្នភាពការរកឃើញ និងកត់ត្រាការឆ្លើយតបនៃសំណើក៏ដូចជាការផ្តល់សក្ខីកម្មផងដែរ រហូតដល់ក្រុមប្រឹក្សាភិបាលចេញសេចក្តីសម្រេចស្ថាពរ។ លើសពីនេះទៀត បទប្បញ្ញត្តិនឹងទទួលស្គាល់ថា ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងអាចបញ្ចូលឯកសារមួយចំនួនដោយយោងទៅលើកំណត់ត្រាភស្តុតាងរបស់ខ្លួន។

បុគ្គលិកដាក់ស្នើផ្នែករងថ្មីចំនួនពីរ ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តបច្ចុប្បន្ន។ បទប្បញ្ញត្តិនឹងរួមបញ្ចូលផ្នែកស្តីពីឯកសារអនុលោមភាព និងឯកសារផ្លាស់ប្តូរគម្រោង ហើយនឹងបញ្ជាក់ដំណើរការដែលទាក់ទងនឹងឯកសារទាំងនេះ។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងរួមបញ្ចូលច្បាប់ស្តីពីការរុះរើ និងការស្តារទីតាំងឡើងវិញ ដែលនឹងកំណត់នូវហេដ្ឋារចនាសម្ព័ន្ធដែលត្រូវរើចេញ ពេលវេលាសម្រាប់ការរើចេញ ការប៉ាន់ប្រមាណថ្លៃចំណាយលើការរុះរើនិងការស្តារទីតាំងឡើងវិញ និងឧបករណ៍ហិរញ្ញវត្ថុដែលបានស្នើឡើង ដើម្បីធានាបាននូវការផ្តល់មូលនិធិលើសកម្មភាពការរុះរើនិងស្តារឡើងវិញនេះ។

<u>ការប្រតិបត្តិបទប្បញ្ញត្តិអាជីវកម្មរបស់ក្រុមប្រឹក្សាភិបាល ក្រម CMR មាត្រា 980 ផ្នែក 2.00</u>៖ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើការផ្លាស់ប្តូរចំពោះក្រម CMR មាត្រា 980 ផ្នែក 2.00 ដើម្បីរួមបញ្ចូលលក្ខខណ្ឌតម្រូវពីក្នុងច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 និងការធ្វើបច្ចុប្បន្នភាពដំណើរការរបស់ក្រុមប្រឹក្សាភិបាល។ ការផ្លាស់ប្តូរទាំងនេះនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2026។

បុគ្គលិកក្រុមប្រឹក្សាភិបាលស្នើឱ្យកែប្រែសមាជិកភាពពីសមាជិក 9 រូប រួមមានសមាជិកសាធារណៈ 6 រូប និងឯកជន 3 រូប ដើម្បីឆ្លុះបញ្ចាំងពីសមាសភាពក្រុមប្រឹក្សាភិបាលថ្មីដែលបានពិពណ៌នានៅក្នុងច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ឱ្យទៅជាសមាជិក 11 រូប រួមមានសមាជិកសាធារណៈ 7 នាក់ និងសមាជិកឯកជន 4 រូប។ ការផ្លាស់ប្តូរនឹងធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវកូរ៉ុមពីសមាជិក 4 រូបទៅ 6 រូប។ បទប្បញ្ញត្តិនេះក៏នឹងកែប្រែគោលបំណងរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង និងបន្ថែមវិសាលភាពថ្មីនៃផ្នែកត្រួតពិនិត្យដែលស្របនឹងអាណត្តិច្បាប់លក្ខន្តិកថ្មីពីច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ។ បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើឱ្យបទប្បញ្ញត្តិនោះបញ្ជាក់ថាការសេចក្តីសម្រេចស្ថាពររបស់ខ្លួនរួមបញ្ចូលលទ្ធផលចាំបាច់នានាដូចបានកំណត់នៅក្នុងច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ។

បទប្បញ្ញត្តិដែលបានស្នើឡើងនឹងរួមបញ្ចូលបញ្ញត្តិច្បាប់លក្ខន្តិកដែលអនុគ្រោះដល់សកម្មភាពណាមួយរបស់ក្រុមប្រឹក្សាភិបាល ឬបុគ្គលផ្សេងទៀតណាម្នាក់ អនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J ដល់ 69J¼ ឬច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T ដល់ 69W ឱ្យរួចផុតពីការពិនិត្យឡើងវិញនៅក្រោមច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាឈូសេត ច្បាប់ទូទៅ ជំពូក 30 ផ្នែក 61 ដល់ 62L ។

បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ស្នើឱ្យបន្តការអនុវត្តដែលមានស្រាប់របស់ខ្លួនសម្រាប់ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសាធារណៈ និងស្នើឱ្យធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិដើម្បីរួមបញ្ចូលនូវសេចក្តីយោងថ្មីៗបំផុតទៅលើច្បាប់ស្តីអំពីកិច្ចប្រជុំដែលបើកចំហរបស់រដ្ឋម៉ាសាឈូសិត។ សំណើនេះក៏បញ្ជាក់ផងដែរថា សមាជិកក្រុមប្រឹក្សាភិបាលអាចចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបែបចម្រុះតាមអនឡាញ ហើយថាក្រុមប្រឹក្សាភិបាលនឹងផ្តល់ជម្រើសផ្សេងទៀតដល់សាធារណជនក្នុងចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនេះតាមរយៈការរៀបចំកិច្ចប្រជុំដែលអាចចូលរួមដោយផ្ទាល់ឬតាមអនឡាញបាន។[3]

---

[3] វិធានរបស់អគ្គរដ្ឋអាជ្ញាចែងថា ស្ថាប័នសាធារណៈអាចបន្តផ្តល់ "មធ្យោបាយជំនួសសមស្រប" ផ្សាយផ្ទាល់នៃការចូលរួមក្នុងកិច្ចពិភាក្សារបស់ស្ថាប័នសាធារណៈ ជំនួសឱ្យការ

បទប្បញ្ញត្តិនេះនឹងរួមបញ្ចូលផ្នែកថ្មីមួយដែលឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៅក្នុងច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ដែលក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបង្កើត និងរក្សាផ្ទាំងព័ត៌មានអនឡាញដែលរួមបញ្ចូលព័ត៌មានអំពីដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ហើយធានាថាទិន្នន័យ និងព័ត៌មានគ្រប់ជ្រុងជ្រោយត្រូវបានផ្តល់ជូនជាសាធារណៈជាទម្រង់ដែលម៉ាស៊ីនអាចអានទិន្នន័យនោះបាន។[4]

B. <u>បទប្បញ្ញត្តិថ្មី</u>

<u>ក្រុម CMR មាត្រា 980 ផ្នែក 13.00៖ លិខិតអនុញ្ញាតរួមសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។</u>

បុគ្គលិកក្រុមប្រឹក្សាក្រុមប្រឹក្សាភិបាលកំណត់ទីតាំងដាក់ស្នើផ្នែកថ្មីនៅក្នុងក្រុមបទប្បញ្ញត្តិរដ្ឋម៉ាសាឈូសិត ("CMR") សម្រាប់ពាក្យសុំដែលបានដាក់ជូន អនុលោមតាមផ្នែកលក្ខន្តិកថ្មីច្បាប់ទូទៅ ជំពូក 164 ផ្នែក69T, 69U, 69V ។ បទប្បញ្ញត្តិទាំងនេះនឹងអនុវត្តចំពោះពាក្យស្នើសុំលិខិតអនុញ្ញាតរួមសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត លើកលែងតែមានការជូនដំណឹងផ្សេងទៀតផ្ទុយពីនេះ។ កាលបរិច្ឆេទចូលជាធរមាននៃបទប្បញ្ញត្តិនេះគឺថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 ហើយនឹងអនុវត្តចំពោះគម្រោងដែលបានដាក់នៅថ្ងៃ ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026។ បទប្បញ្ញត្តិដែលបានស្នើឡើងនឹងអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំដាក់ពាក្យសុំទៅកាន់ក្រុមប្រឹក្សាកំណត់ទីតាំងដោយអនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T, 69U និងអនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69V នៅពេលបង្ហាញពីមូលហេតុសមស្រប។

បទប្បញ្ញត្តិដែលបានស្នើឡើង នឹងហាមឃាត់អ្នកដាក់ពាក្យសុំមិនឱ្យចាប់ផ្តើមសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំដោយមិនទទួលលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាលជាមុន។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានស្នើសុំលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលស្អាតខ្នាតតូចស្របតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69U អ្នកដាក់ពាក្យមិនអាចចាប់ផ្តើមការសាងសង់ដោយមិនបានទទួលលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំងឡើយ។

បទប្បញ្ញត្តិដែលបានស្នើឡើង នឹងរួមបញ្ចូលលក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធបញ្ជូននិងចែកចាយថាមពលស្អាតខ្នាតធំ ឬលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាលសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធការបញ្ជូន និងចែកចាយស្អាតខ្នាតតូច។ ក្រៅពីនោះ បទប្បញ្ញត្តិដែលបានស្នើឡើងនឹងរួមបញ្ចូលលក្ខខណ្ឌដាក់ពាក្យសុំសម្រាប់ទីតាំងរោងចក្រផលិតថាមពលស្អាតខ្នាតធំ ឬកន្លែងស្តុកថាមពលស្អាតខ្នាតធំ ឬលិខិតអនុញ្ញាតរួមថ្នាក់រដ្ឋសម្រាប់ទីតាំងរោងចក្រផលិតថាមពលស្អាតខ្នាតតូច ឬកន្លែងស្តុកថាមពលស្អាតខ្នាតតូច។

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងពិនិត្យមើលពាក្យសុំ និងធ្វើការសម្រេចក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការដាក់ពាក្យសុំ ថាតើពាក្យសុំមានលក្ខណៈពេញលេញដែរឬទេ។ បទប្បញ្ញត្តិនឹងកំណត់កត្តាដែលមន្ត្រីវិនិច្ឆ័យសេចក្តីនឹងធ្វើការសម្រេចលើភាពពេញលេញ។ កត្តាមួយចំនួនក្នុងការកំណត់ភាពពេញលេញនឹងអាចរួមបញ្ចូល

---

ប្រជុំនៅកន្លែងសាធារណៈបើកចំហ ហើយសាធារណៈជនអាចចូលរួមបាន។ ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង រៀបចំការប្រជុំក្រុមប្រឹក្សាភិបាលរបស់ខ្លួនជាកិច្ចប្រជុំបែបចម្រុះ ដោយមានទាំងការចូលរួមដោយផ្ទាល់និងតាមអនឡាញ។

4 សូមមើល https://www.mass.gov/info-details/executive-office-of-energy-environmental-affairs-ensuring-meaningful-access-for-persons-with-disabilities-policy.

ទាំងថាតើពាក្យសុំនោះ (i) មានការពិពណ៌នាត្រឹមត្រូវនិងពេញលេញអំពីទីកន្លែង ទីតាំង និងតំបន់ជុំវិញដែរឬទេ។ (ii) មានភស្តុតាងបញ្ជាក់ពីការបំពេញទាំងស្រុងតាមលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំដែរឬទេ។ (iii) មានរាល់លក្ខខណ្ឌតម្រូវការដាក់ពាក្យសុំទាំងអស់ រួមទាំងព័ត៌មានគ្រប់គ្រាន់ដើម្បីឱ្យទីភ្នាក់ងាររដ្ឋនិងមូលដ្ឋានផ្តល់សេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដែលបានណែនាំដែរឬទេ។ និង (iv) ភស្តុតាងគ្រប់គ្រាន់ដើម្បីឱ្យក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបង្កើតលទ្ធផលស្រាវជ្រាវដែលបានកំណត់ដែរឬទេ។ បទប្បញ្ញត្តិនេះនឹងអនុញ្ញាតឱ្យមន្ត្រីវិនិច្ឆ័យសេចក្តីអាចពង្រីកកាលវិភាគពិនិត្យមើលភាពពេញលេញនោះនៅពេលបង្ហាញពីស្ថានភាពពិសេស ឬបង្ហាញពីមូលហេតុសមស្រប។ ក្នុងករណីដែលមន្ត្រីវិនិច្ឆ័យសេចក្តីកំណត់ថាពាក្យសុំមិនពេញលេញ ហើយត្រូវបានបដិសេធនោះ បទប្បញ្ញត្តិនេះនឹងផ្តល់ឱកាសឱ្យអ្នកដាក់ពាក្យសុំធ្វើការស្នើសុំឱ្យលេខាធិការពិនិត្យឡើងវិញទៅលើការបដិសេធពាក្យសុំរបស់ខ្លួន។

ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងបង្កើតកាលវិភាគនីតិវិធីស្តង់ដាដែលនឹងបង្ហាញភាពច្បាស់លាស់ដល់ភាគីថាតើនៅពេលណាដែលព្រឹត្តិការណ៍សំខាន់ៗនឹងកើតឡើងនៅក្នុងដំណើរការនីតិវិធីមួយ។ កាលវិភាគស្តង់ដាក៏នឹងធានាផងដែរថាក្រុមប្រឹក្សាភិបាលនឹងបំពេញកាតព្វកិច្ចតាមច្បាប់របស់ខ្លួនក្នុងការបញ្ចប់ការត្រួតពិនិត្យគម្រោងនៅក្នុងរយៈពេលដែលបានកំណត់ក្នុងលក្ខន្តិកៈ (ឧ. ចន្លោះពី 6 ទៅ 15 ខែ)។ នៅក្នុងកាលវិភាគស្តង់ដាទាំងនេះ មន្ត្រីវិនិច្ឆ័យសេចក្តីអាចកែសម្រួលកាលវិភាគសម្រាប់ដំណើរការជាក់លាក់មួយ ដើម្បីឆ្លុះបញ្ចាំងពីភាពជាក់លាក់នៃគម្រោងណាមួយ ឬតាមការស្នើសុំរបស់ភាគីណាមួយ។

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ទទួលស្គាល់ជំនាញ និងចំណាប់អារម្មណ៍របស់ភ្នាក់ងារអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាននៅក្នុងគម្រោងដែលបានស្នើឡើង។ បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង នឹងឆ្លុះបញ្ចាំងពីផលប្រយោជន៍ដែលជាប់ពាក់ព័ន្ធនេះ ហើយនឹងចាត់ទុកថាភ្នាក់ងារទាំងនេះទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬយ៉ាងខ្លាំងពីដំណើរការនីតិវិធីនេះ។ ភ្នាក់ងារ ឬទីក្រុងសាមីអាចជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលអំពីបំណងរបស់ខ្លួនក្នុងការធ្វើអន្តរាគមន៍ក្នុងដំណើរការនីតិវិធីនេះ ហើយមន្ត្រីវិនិច្ឆ័យសេចក្តីនឹងផ្តល់សិទ្ធិជាអន្តរការីដល់ទីភ្នាក់ងារនៅក្នុងដំណើរការនីតិវិធីពិនិត្យមើលពាក្យសុំរបស់ទីតាំង។ បទប្បញ្ញត្តិដែលបានស្នើឡើងក៏អនុញ្ញាតឱ្យភ្នាក់ងារអនុញ្ញាតប្រគល់សេចក្តីថ្លែងបញ្ជាក់អំពីលក្ខខណ្ឌអនុញ្ញាតដែលបានណែនាំទៅឱ្យក្រុមប្រឹក្សាភិបាលទាក់ទងទៅនឹងលិខិតអនុញ្ញាតរៀងៗខ្លួនដែលទីភ្នាក់ងារនីមួយៗនឹងទទួលខុសត្រូវចេញលិខិតនោះ។ សេចក្តីថ្លែងបញ្ជាក់អំពីលក្ខខណ្ឌអនុញ្ញាតដែលបានណែនាំ ត្រូវរួមបញ្ចូលលក្ខខណ្ឌដែលបានណែនាំណាមួយដែលទីភ្នាក់ងារស្នើឱ្យរួមបញ្ចូលជាមួយលក្ខខណ្ឌស្តង់ដាររបស់ក្រុមប្រឹក្សាភិបាល ដើម្បីចេញលិខិតអនុញ្ញាតនោះ។ សេចក្តីថ្លែងបញ្ជាក់ពីលក្ខខណ្ឌអនុញ្ញាតដែលបានណែនាំ ត្រូវរាប់បញ្ចូលទាំងការទាញហេតុផលគាំទ្រសម្រាប់លក្ខខណ្ឌ និងឯកសារគាំទ្រ ប្រសិនបើសមស្រប។ ជាចុងក្រោយ បទប្បញ្ញត្តិនឹងចាត់តាំងកិច្ចការអនុវត្តលក្ខខណ្ឌសម្រាប់គម្រោងនោះទៅឱ្យភ្នាក់ងារអនុញ្ញាត។

<u>ក្រុម CMR មាត្រា 980 ផ្នែក 14.00៖ ការវិនិច្ឆ័យសាជាថ្មីលើការស្នើសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋាន។</u>

បុគ្គលិកក្រុមប្រឹក្សាកំណត់ទីតាំងស្នើឱ្យប្រកាសឱ្យប្រើបទប្បញ្ញត្តិដែលកំណត់ដំណើរការសម្រាប់ការវិនិច្ឆ័យសាជាថ្មីនៅចំពោះមុខអភិបាលនៃក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ទៅលើពាក្យសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋានសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69G, 69W។ បទប្បញ្ញត្តិនេះនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 ហើយនឹងអនុវត្តចំពោះគម្រោងដែលបានដាក់ស្នើនៅថ្ងៃ ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026។

បទប្បញ្ញត្តិដែលបានស្នើឡើងនឹងកំណត់អ្នកដែលអាចស្នើសុំការវិនិច្ឆ័យសាជាថ្មីលើពាក្យសុំលិខិតអនុញ្ញាតរួមថ្នាក់មូលដ្ឋាន៖ (1) ម្ចាស់ ឬម្ចាស់សំណើនៃទីតាំងហេដ្ឋារចនាសម្ព័ន្ធ

ថាមពលស្អាតខ្នាតតូច ដែលបានទទួលការសម្រេចចុងក្រោយ ឬមានការយល់ព្រមក្នុងន័យស្ថាបនាទៅលើពាក្យសុំលិខិតអនុញ្ញាតរួមពីរដ្ឋាភិបាលមូលដ្ឋាន។ និង (2) ភាគីរងផលប៉ះពាល់សំខាន់ និងជាពិសេសតាមរយៈការសម្រេចចិត្តរបស់រដ្ឋាភិបាលមូលដ្ឋាន ឬការយល់ព្រមក្នុងន័យស្ថាបនាថ្នាក់មូលដ្ឋាន។ លើសពីនេះ បទប្បញ្ញត្តិដែលបានស្នើឡើងនឹងចែងថា នៅពេលដែលបង្ហាញថាធនធាន សមត្ថភាព និងបុគ្គលិករបស់ខ្លួនមិនអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញលើពាក្យស្នើសុំលិខិតអនុញ្ញាតរបស់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចក្នុងរយៈពេលកំណត់អតិបរមា 12 ខែសម្រាប់ការត្រួតពិនិត្យរបស់រដ្ឋាភិបាលមូលដ្ឋាននោះទេ រដ្ឋាភិបាលមូលដ្ឋានអាចស្នើសុំការវិនិច្ឆ័យសាជាថ្មីពីអភិបាលនៃក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបាន។ បទប្បញ្ញត្តិនេះនឹងកំណត់កាលបរិច្ឆេទផុតកំណត់សម្រាប់ការស្នើសុំការវិនិច្ឆ័យសាជាថ្មី។

បទប្បញ្ញត្តិដែលបានស្នើឡើងនេះ នឹងផ្តល់ការជូនដំណឹងអំពីសំណើសម្រាប់ការវិនិច្ឆ័យសាជាថ្មី និងរយៈពេលសម្រាប់ការបញ្ចេញមតិជាលាយលក្ខណ៍អក្សរ។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 មិនតម្រូវឱ្យអភិបាលធ្វើសវនាការស្តាប់មតិយោបល់សាធារណៈនោះទេ។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិក៏នឹងអនុញ្ញាតឱ្យអភិបាលធ្វើសវនាការស្តាប់មតិយោបល់សាធារណៈ ដែលអាចប្រព្រឹត្តទៅជាសវនាការតាមអនឡាញ។ បទប្បញ្ញត្តិនេះក៏នឹងអនុញ្ញាតឱ្យមានអន្តរាគមន៍ពីបុគ្គល ឬអង្គភាពដែលអាចបង្ហាញថាខ្លួនទទួលរងផលប៉ះពាល់យ៉ាងខ្លាំង និងដោយផ្ទាល់។

កំណត់ត្រាភស្តុតាងត្រូវរាប់បញ្ចូលទាំងឯកសារដែលបង្កើតឡើងសម្រាប់ដំណើរការលិខិតការអនុញ្ញាតរួមថ្នាក់មូលដ្ឋាន និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលត្រូវបានអនុញ្ញាតដោយអភិបាល។ អភិបាលនឹងចេញកាលវិភាគនីតិវិធីដែលរួមមានកាលវេលាកំណត់ និងការកំណត់បញ្ហាដែលត្រូវវិនិច្ឆ័យសេចក្តី។ អភិបាលអាចកំណត់ពេលសវនាការលើភស្តុតាងតាមអនឡាញបាន។

អភិបាលត្រូវពិនិត្យសំណើសុំការវិនិច្ឆ័យសាជាថ្មី និងការសម្រេចចិត្តចុងក្រោយរបស់រដ្ឋាភិបាលមូលដ្ឋានសម្រាប់៖ (a) ភាពស្របគ្នាទៅនឹងបទប្បញ្ញត្តិដែលអនុម័តស្តង់ដាអនុញ្ញាតទូទាំងរដ្ឋសម្រាប់ទីតាំងទាំងឡាយដែលបង្កើតឡើងដោយនាយកដ្ឋានធនធានថាមពល ស្របតាមច្បាប់ទូទៅ ជំពូក 25A ផ្នែក 21 និង (b) ភាពស្របគ្នាទៅនឹងច្បាប់ទូទៅ ជំពូក 164 ផ្នែក 69H ។

បន្ទាប់ពីពិនិត្យរួច អភិបាលនៃក្រុមប្រឹក្សាភិបាលត្រូវចេញសេចក្តីសម្រេចលើសំណើសុំពីម្ចាស់ ឬម្ចាស់សំណើនៃទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច ដែលបានទទួលសេចក្តីសម្រេចស្ថាពរ ឬមានការយល់ព្រមក្នុងន័យស្ថាបនាទៅលើពាក្យសុំលិខិតអនុញ្ញាតរួមពីរដ្ឋាភិបាលមូលដ្ឋាន ឬពីភាគីនានាដែលរងផលប៉ះពាល់យ៉ាងខ្លាំង និងជាពិសេសតាមរយៈការសម្រេចចិត្តរបស់រដ្ឋាភិបាលមូលដ្ឋាន ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការទទួលពាក្យសុំ ហើយការសម្រេចចិត្តនោះត្រូវចូលជាស្ថាពរ។ អភិបាលត្រូវចេញសេចក្តីសម្រេចលើសំណើពីរដ្ឋាភិបាលមូលដ្ឋាននៅពេលបង្ហាញថាធនធាន សមត្ថភាព និងបុគ្គលិករបស់ខ្លួនមិនអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញលើពាក្យស្នើសុំលិខិតអនុញ្ញាតរបស់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចក្នុងរយៈពេលកំណត់អតិបរមា 12 ខែសម្រាប់ការត្រួតពិនិត្យរបស់រដ្ឋាភិបាលមូលដ្ឋាននោះទេ។ ការសម្រេចចិត្តរបស់អភិបាលត្រូវធ្វើឡើងក្នុងរយៈពេលដប់ពីរខែបន្ទាប់ពីបានទទួលពាក្យសុំ ហើយការសម្រេចនោះត្រូវចូលជាស្ថាពរ។ ដើម្បីបំពេញតាមកាលវិភាគដែលកំណត់ដោយច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលនឹងរួមបញ្ចូលនូវការសម្រេចចិត្តស្ថាពរពីអភិបាល និងមិនរួមបញ្ចូលនូវការសម្រេចចិត្តបណ្តោះអាសន្ន ឬមតិយោបល់លើការសម្រេចចិត្តបណ្តោះអាសន្ននោះទេ។

C. ការលុបចោលបទប្បញ្ញត្តិដែលមិនប្រើ

បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលមានផ្នែកមួយចំនួនដែលផុតសុពលភាព និងមិនត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាលក្នុងរយៈពេលជាច្រើនឆ្នាំ។ ដើម្បីឱ្យកាន់តែច្បាស់ ក្រុមប្រឹក្សាភិបាលស្នើឱ្យលុបចោលផ្នែកខាងក្រោមនេះ៖

ក្រម CMR មាត្រា 980 ផ្នែក 4.00៖ សេរីភាពនៃព័ត៌មាន ការការពារការសម្ងាត់ពាណិជ្ជកម្ម
ក្រម CMR មាត្រា 980 ផ្នែក 5.00៖ ការវាយតម្លៃបរិស្ថាន និងផលប៉ះពាល់បរិស្ថាន
ក្រម CMR មាត្រា 980 ផ្នែក 7.00៖ ការព្យាករណ៍រយៈពេលវែង និងការបំពេញបន្ថែម
ក្រម CMR មាត្រា 980 ផ្នែក 8.00៖ សេចក្តីជូនដំណឹងអំពីបំណងក្នុងការសាងសង់ទីតាំងរោងចក្រប្រេង
ក្រម CMR មាត្រា 980 ផ្នែក 9.00 ការជ្រើសរើស ការវាយតម្លៃ និងការប៉ាន់ប្រមាណ
ក្រម CMR មាត្រា 980 ផ្នែក 11.00៖ ការផ្តល់អាជ្ញាបណ្ណទីតាំងរោងចក្រផលិតថាមពលវារីអគ្គិសនី

<u>សូមមើល</u> ឧបសម្ព័ន្ធទី 1 សម្រាប់ហេតុផលដែលបុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងស្នើឱ្យលុបចោលបទប្បញ្ញត្តិទាំងនេះ។

IV. <u>សំណើសុំមតិយោបល់</u>

- បទប្បញ្ញត្តិក្រុមប្រឹក្សាភិបាលដែលមានស្រាប់ តម្រូវឱ្យមានការជូនដំណឹងតាមកាសែតអំពីសវនាការស្តាប់មតិយោបល់សាធារណៈ។ តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគួរលុបចោលលក្ខខណ្ឌតម្រូវសម្រាប់ការជូនដំណឹងតាមកាសែតអំពីសវនាការស្តាប់មតិយោបល់សាធារណៈដែរឬទេ?
  តើការជូនដំណឹងប្រភេទណាមានប្រសិទ្ធភាពជាងសម្រាប់សវនាការទាំងនេះ?
- តើការចុះទស្សនកិច្ចដល់ទីតាំងរបស់បុគ្គលិកក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនៅតាមទីតាំងគម្រោងដែលបានស្នើ គួរតែបើកឱ្យសាធារណជនចូលរួមដែរឬទេ? តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងគ្រប់គ្រងដំណើរការនេះដោយរបៀបណា?
- តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគួររួមបញ្ចូលសកម្មភាពលុបចោលគម្រោង និងការរំពឹងទុកចំពោះសកម្មភាពនោះយ៉ាងដូចម្តេច?
- នៅពេលបង្ហាញថាធនធាន សមត្ថភាព និងបុគ្គលិករបស់ខ្លួនមិនអនុញ្ញាតឱ្យពិនិត្យឡើងវិញលើពាក្យសុំលិខិតអនុញ្ញាតរបស់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចក្នុងរយៈពេលកំណត់អតិបរមា 12 ខែសម្រាប់ការពិនិត្យឡើងវិញរបស់រដ្ឋាភិបាលមូលដ្ឋានក្នុងករណីដែលរដ្ឋាភិបាលមូលដ្ឋានអាចស្នើសុំការវិនិច្ឆ័យសាជាថ្មីពីអភិបាលនៃក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបាន តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគួរតែបង្កើតកាលវិភាគរយៈពេល 12 ខែសម្រាប់ការត្រួតពិនិត្យ ស្របតាមកាលវិភាគ 12 ខែដែលបានអនុញ្ញាតសម្រាប់ការត្រួតពិនិត្យនៅថ្នាក់មូលដ្ឋានដែរឬទេ?
- សម្រាប់ការវិនិច្ឆ័យសាជាថ្មី តើបទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាលគួរតែផ្តល់ឱកាសឱ្យមានសំណើសុំការពិចារណាឡើងវិញពីអភិបាលទៅលើការសម្រេចស្ថាពរក្នុងពេលវិនិច្ឆ័យសេចក្តីសាជាថ្មីដែរឬទេ?
- នីតិវិធីអនុញ្ញាតសម្រាប់ទីតាំងថាមពលនៅក្នុងរដ្ឋផ្សេងទៀត រួមបញ្ចូលនូវជំហាននានាដែលកំណត់វិសាលភាពកម្មវត្ថុដែលអាចនឹងយកមកពិភាក្សាក្នុងអំឡុងពេលវិនិច្ឆ័យសេចក្តី ហើយត្រូវបានសម្រេចលើលិខិតអនុញ្ញាតចុងក្រោយនោះ។ ដែនកំណត់នេះអាចបង្កើនប្រសិទ្ធភាពសម្រាប់ការចេញលិខិតអនុញ្ញាត។ តើក្រុមប្រឹក្សាកំណត់ទីតាំងគួរទទួលយកការអនុវត្តបែបនេះដែរឬទេ? តើដែនកំណត់នៃការអនុវត្តអ្វីខ្លះដែលក្រុមប្រឹក្សាកំណត់ទីតាំងគួរពិចារណា? ចូរពិពណ៌នាអំពីឧបសគ្គផ្លូវច្បាប់ណាមួយសម្រាប់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងក្នុងការអនុម័តការអនុវត្តស្រដៀងគ្នានេះ។

**ឧបសម្ព័ន្ធទី 1 - សំណើលុបចោលបទប្បញ្ញត្តិដែលមាន ស្រាប់**

**<u>ក្រុម CMR មាត្រា 980 ផ្នែក 4.00៖ សេរីភាពនៃព័ត៌មាន ការការពារការសម្ងាត់ពាណិជ្ជកម្ម</u>**

ក្រុម CMR មាត្រា 980 ផ្នែក 4.00៖ សេរីភាពនៃព័ត៌មាន, ការការពារការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សាកំណត់ទីតាំងឋបនីយភណ្ឌថាមពលនៅឆ្នាំ 1975 និងហួសសុពលភាព ហើយលែងប្រើទៀតហើយ។ ព័ត៌មានដែលក្រុមប្រឹក្សាភិបាល EFSB បានរក្សាទុក អាចស្វែងរកបានជាសាធារណៈនៅលើគេហទំព័ររបស់ខ្លួន។ លើសពីនេះ ការឆ្លើយតបទៅនឹងសំណើសុំកំណត់ត្រាសាធារណៈត្រូវបានប្រមូលផ្តុំ ហើយមន្ត្រីរក្សាកំណត់ត្រាសាធារណៈធានានូវការឆ្លើយតបបានទាន់ពេលវេលា។ តម្រូវការសម្រាប់ការការពារព័ត៌មានសម្ងាត់មានចែងនៅក្នុងវិធានជាមូលដ្ឋានសម្រាប់នីតិវិធីនីមួយៗ។

**<u>ក្រុម CMR មាត្រា 980 ផ្នែក 5.00៖ ការវាយតម្លៃបរិស្ថាន និងផលប៉ះពាល់បរិស្ថាន</u>**

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 នឹងរួមបញ្ចូលបញ្ញត្តិច្បាប់លក្ខន្តិកដែលអនុគ្រោះដល់សកម្មភាពណាមួយរបស់ក្រុមប្រឹក្សាភិបាល ឬបុគ្គលផ្សេងទៀតណាម្នាក់ អនុលោមតាមច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J ដល់ 69J¼ ឬច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T ដល់ 69W ឱ្យរួចផុតពីការពិនិត្យឡើងវិញនៅក្រោមច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាឈូសេត ច្បាប់ទូទៅ ជំពូក 30 ផ្នែក 61 ដល់ 62L ។ ដូច្នេះ បទប្បញ្ញត្តិនេះលែងចាំបាច់ទៀតហើយ។

**<u>ក្រុម CMR មាត្រា 980 ផ្នែក 7.00៖ ការព្យាករណ៍រយៈពេលវែង និងការបំពេញបន្ថែម</u>**

ក្រុម CMR មាត្រា 980 ផ្នែក 7.00៖ ការព្យាករណ៍និងការផ្គត់ផ្គង់បន្ថែមរយៈពេលវែងពិពណ៌នាអំពីដំណើរការរៀបចំផែនការសម្រាប់ក្រុមហ៊ុនឧស្ម័ននិងអគ្គិសនីដែលក្រុមប្រឹក្សាភិបាល EFSB មិនបានប្រើប្រាស់ចាប់តាំងពីឆ្នាំ 1991 នៅពេលដែលក្រុមប្រឹក្សាកំណត់ទីតាំងឋបនីយភណ្ឌថាមពលត្រូវបានផ្លាស់ប្តូរតាមបែបរដ្ឋបាលទៅជានាយកដ្ឋាន DPU ហើយប្តូរឈ្មោះទៅជាក្រុមប្រឹក្សាភិបាល EFSB ។ ដូចបានអនុវត្តក្រោមក្រុម CMR មាត្រា 980 ផ្នែក 7.00 សម្រាប់ក្រុមហ៊ុនអគ្គិសនី ផែនការរយៈពេលវែងបានបញ្ចប់ជាមួយនឹងការមកដល់នៃការគ្រប់គ្រងធនធានរួមបញ្ចូលគ្នានៅដើមទសវត្សរ៍ឆ្នាំ 1990 ហើយត្រូវបានបញ្ឈប់ជាផ្លូវការដោយមានការរៀបចំរចនាសម្ព័ន្ធអគ្គិសនីឡើងវិញនៅចុងទសវត្សរ៍ឆ្នាំ 1990 ។ សម្រាប់ក្រុមហ៊ុនឧស្ម័ន ដំណើរការរៀបចំផែនការព្យាករណ៍និងផ្គត់ផ្គត់នៅតែត្រូវបានពិនិត្យដោយនាយកដ្ឋាន DPU (មិនមែនត្រួតពិនិត្យដោយក្រុមប្រឹក្សា EFSB ទេ)។ ក្រុម CMR មាត្រា 980 ផ្នែក 7.00 មិនត្រូវបានប្រើប្រាស់ទាល់តែសោះនៅក្នុងដំណើរការបច្ចុប្បន្ននេះ ហើយនាយកដ្ឋាន DPU មិនត្រូវការបទប្បញ្ញត្តិនេះទេ។

**<u>ក្រុម CMR មាត្រា 980 ផ្នែក 8.00៖ សេចក្តីជូនដំណឹងអំពីបំណងក្នុងការសាងសង់ទីតាំងរោងចក្រប្រេង</u>**

ក្រុម CMR មាត្រា 980 ផ្នែក 8.00៖ សេចក្តីជូនដំណឹងអំពីបំណងសាងសង់ទីតាំងរោងចក្រប្រេងដែលណែនាំអ្នកដាក់ពាក្យស្នើសុំឱ្យស្វែងរកការយល់ព្រមពីក្រុមប្រឹក្សាភិបាល EFSB ក្នុងការសាងសង់កន្លែងស្តុកប្រេងខ្នាតធំ (ចំណុះជាង 21 លានហ្គាឡុង) និងបំពង់បង្ហូរប្រេងថ្មីដែលមានប្រវែងជាងមួយម៉ាយ មិនត្រូវបានប្រើប្រាស់ចាប់តាំងពីការប្រកាសឱ្យប្រើច្បាប់នៅឆ្នាំ 1975 ។ ការប្រើប្រាស់ប្រេងឥន្ធនៈនៅរដ្ឋម៉ាសាឈូសិតបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈ

ពេលជាច្រើនទស្សវត្សកន្លងមកនេះ ហើយអវត្តមាននៃទីតាំងរោងចក្រប្រេងក្នុងដែនយុត្តាធិការថ្មីដែលបានស្នើឡើង បាននាំឱ្យមានកង្វះការប្រើប្រាស់បទប្បញ្ញត្តិនេះ។

លើសពីនេះ កន្លែងស្តុកប្រេងនិងបំពង់បង្ហូរប្រេងនឹងត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់សហព័ន្ធនិងរដ្ឋ។ សុវត្ថិភាពបំពង់បង្ហូរប្រេង និងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់របស់ក្រសួងដឹកជញ្ជូនសហរដ្ឋអាមេរិក មានបទប្បញ្ញត្តិលម្អិតដែលគ្រប់គ្រងលើសារធាតុគ្រោះថ្នាក់ (ក្រម CF R មាត្រា 49 ផ្នែក 100 ដល់ 185) និងបទប្បញ្ញត្តិលម្អិតស្តីពីសុវត្ថិភាពបំពង់បង្ហូរប្រេង (49 ផ្នែក CFR ផ្នែក 190-199) ។ លើសពីនេះ ការសាងសង់ទីតាំងរោងចក្រប្រេង ឬបំពង់បង្ហូរប្រេង នឹងត្រូវគ្រប់គ្រងដោយក្រមសុវត្ថិភាពអគ្គីភ័យលម្អិតរបស់រដ្ឋម៉ាសាឈូសិត ក្រម CMR មាត្រា 527 ផ្នែក 1.01 និងផ្នែកបន្តបន្ទាប់ និងក្រមស្តីពីការ សាងសង់របស់រដ្ឋម៉ាសាឈូសិត ក្រម CMR មាត្រា 780 ផ្នែក 101.1 និងផ្នែកបន្តបន្ទាប់។

## ក្រម CMR មាត្រា 980 ផ្នែក 9.00 ការជ្រើសរើស ការវាយតម្លៃ និងការប៉ាន់ប្រមាណ

ក្រម CMR មាត្រា 980 ផ្នែក 9.00៖ ការជ្រើសរើស ការវាយតម្លៃ និងការប៉ាន់ប្រមាណទីតាំងតំបន់ឆ្នេរត្រូវបានអនុម័តនៅឆ្នាំ 1975 បន្ទាប់ពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងក្រុមប្រឹក្សាកំណត់ទីតាំងបបនីយភណ្ឌថាមពល (ជាឈ្មោះពីមុនរបស់ក្រុមប្រឹក្សាភិបាល EFSB) និងលេខាធិការនៃការិយាល័យប្រតិបត្តិនៃកិច្ចការបរិស្ថាន។ គោលបំណងចម្បងនៃ MOU និងបទប្បញ្ញត្តិពាក់ព័ន្ធ ក្រម CMR មាត្រា 980 ផ្នែក 9.00 គឺដើម្បីធានាថាក្រុមប្រឹក្សាភិបាលកំណត់ទីតាំងនឹងអនុម័ត និងអនុវត្តគោលការណ៍ដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការគ្រប់គ្រងតំបន់ឆ្នេររដ្ឋម៉ាសាឈូសិត ក្នុងការសម្រេចចិត្តរបស់ខ្លួន។ គោលបំណងជាមូលដ្ឋាននៃ MOU និងក្រម CMR មាត្រា 980 ផ្នែក 9.00 ត្រូវបានគោរពតាមដោយលក្ខខណ្ឌច្បាប់លក្ខន្តិកស្តូលរបស់ក្រុមប្រឹក្សាភិបាល ដើម្បីធានាថាការសម្រេចចិត្តខ្លួនមានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយបរិស្ថាន សុខភាព ថាមពល និងការប្រើប្រាស់ធនធានរបស់រដ្ឋម៉ាសាឈូសិត។

## ក្រម CMR មាត្រា 980 ផ្នែក 11.00៖ ការផ្តល់អាជ្ញាបណ្ណទីតាំងរោងចក្រផលិតថាមពលវារីអគ្គិសនី

អាជ្ញាប័ណ្ណទីតាំងរោងចក្រថាមពលវារីអគ្គិសនីត្រូវបានត្រួតពិនិត្យដោយគណៈកម្មការនិយតកម្មថាមពលសហព័ន្ធចាប់តាំងពីឆ្នាំ 1977 និងដោយទីភ្នាក់ងារសហព័ន្ធផ្សេងទៀតមុនពេលនោះ។ ពិតមែនតែភ្នាក់ងារបរិស្ថាននៃរដ្ឋម៉ាសាឈូសិតមានតួនាទីអនុញ្ញាតមួយចំនួនទាក់ទងនឹងវារីអគ្គិសនី ប៉ុន្តែភាគច្រើនគឺជាដែនរបស់រដ្ឋាភិបាលសហព័ន្ធ។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69H1/2 បានបង្កើតក្រុមប្រឹក្សាភិបាល EFSB ជាអង្គភាពសម្របសម្រួល (ជាជាងអង្គភាពអនុញ្ញាត) ដែលនឹងធ្វើការជាមួយភ្នាក់ងាររដ្ឋ និងអ្នកស្នើសុំធ្វើអន្តរាគមន៍ក្នុងដំណើរការផ្តល់អាជ្ញាប័ណ្ណវារីអគ្គិសនីរបស់សហព័ន្ធ។ នៅពេលផ្តល់សិទ្ធិអំណាចនេះ ដំណើរការផ្តល់អាជ្ញាប័ណ្ណរបស់សហព័ន្ធមានភាពស្មាក់ស្មើរ ហើយត្រូវការជំនាញរដ្ឋបាលទូលំទូលាយនៅក្នុងការអនុវត្តរបស់គណៈកម្មាធិការ FERC ។ តួនាទីរបស់ក្រុមប្រឹក្សាភិបាល EFSB ក្នុងការបំពេញតួនាទីសម្របសម្រួល នេះ អាចរកបានតាមសំណើរបស់អ្នកស្នើរសុំ។

គណៈកម្មាធិការ FERC បានធ្វើការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់លើដំណើរការផ្តល់អាជ្ញាប័ណ្ណវារីអគ្គិសនីជាមួយនឹងដំណើរការសហការមុនដាក់ពាក្យសុំក្នុងឆ្នាំ 1997 ដែលមានលក្ខណៈ "ងាយស្រួលប្រើ" និងអំណោយផលដល់ការចូលរួមដោយផ្ទាល់ពីភ្នាក់ងាររដ្ឋ សាធារណជន និងអ្នកដាក់ពាក្យ។ ជាមួយនឹងការមកនៃដំណាក់កាលមុនដាក់ពាក្យសុំ ម្ចាស់សំណើវារីអគ្គិសនីបានបដិសេធជាបន្តបន្ទាប់ក្នុងការប្រើប្រាស់តួនាទីសម្របសម្រួលរបស់ក្រុមប្រឹក្សាភិបាល EFSB

ហើយឥឡូវនេះពួកគេចូលរួមដោយផ្ទាល់ជាមួយគណៈកម្មាធិការ FERC នៅក្នុងដំណើរការរបស់ខ្លួន ។ អស់រយៈពេលជាង 15 ឆ្នាំមកហើយចាប់តាំងពីក្រុមប្រឹក្សាភិបាល EFSB បានមើលឃើញការចូលរួមរបស់ក្រុមប្រឹក្សា EFSB នៅក្នុងសំណើរបស់អ្នកដាក់ពាក្យសុំនៅក្នុងបញ្ហាអាជ្ញាប័ណ្ណវារីអគ្គិសនីរបស់គណៈកម្មាធិការ FERC ។ បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាភិបាល EFSB នៅក្នុងក្រម CMR មាត្រា 980 ផ្នែក 11.00 ភាគច្រើនគឺគឺមានលក្ខណៈស្រួនគ្នាជាមួយនឹងដំណើរការបទប្បញ្ញត្តិសហព័ន្ធដែលប្រើប្រាស់ដោយគណៈកម្មាធិការ FERC ក្នុងការពិនិត្យឡើងវិញនូវទីតាំងថាមពលវារីអគ្គិសនី។

# គំនូសតាងដំហាននីតិវិធីរបស់ EFSB

➤= ចន្លោះពេលពាក្យសុំ

## ដំណើរការរយៈពេល 15 ខែរបស់ EFSB

*អាចអនុវត្តបានចំពោះបរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយធំ (ឧទាហរណ៍)៖*

- *បណ្តាញខ្សែបញ្ជូនថ្មី (≥69 kV) នៅក្នុងច្រករបៀងថ្មី (≥1 ម៉ាយល៍)*
- *បណ្តាញខ្សែបញ្ជូនថ្មី (≥115 kV) នៅក្នុងច្រករបៀងដែលមានស្រាប់ (≥10 ម៉ាយល៍)*
- *ស្ថានីយ៍រងដែលតម្រូវឱ្យមានការលើកលែងពីបទបញ្ញត្តិកំណត់តំបន់ក្នុងមូលដ្ឋាន*
- *បណ្តាញខ្សែតភ្ជាប់សម្រាប់បរិក្ខារទួរប៊ីនខ្យល់នៅឯនាយសមុទ្រ*
- *បរិក្ខារផ្ទុកថាមពលទ្រង់ទ្រាយធំ (≥100 MWh)*
- *បរិក្ខារផលិតថាមពលស្អាតទ្រង់ទ្រាយធំ (≥25 MW)*

## ដំណើរការរយៈពេល 12 ខែរបស់ EFSB

*អាចអនុវត្តបានចំពោះបរិក្ខារហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលស្អាតទ្រង់ទ្រាយតូច (ឧទាហរណ៍)៖*

- *គម្រោងជួសជុល និងសាងសង់ឡើងវិញនូវបណ្តាញខ្សែបញ្ជូន*
- *បណ្តាញខ្សែបញ្ជូនថ្មី/ដែលបានផ្លាស់ប្តូរសំខាន់ៗនៅក្នុងច្រករបៀងដែលមានស្រាប់ (<10 ម៉ាយល៍)*
- *បណ្តាញខ្សែបញ្ជូនដែលបានបញ្ជូនថ្មី/សំខាន់ៗនៅក្នុងច្រករបៀងថ្មី (<1 ម៉ាយល៍)*
- *ស្ថានីយ៍រងដែលមិនតម្រូវឱ្យមានការលើកលែងពីបទបញ្ញត្តិកំណត់តំបន់ក្នុងមូលដ្ឋាន*
- *គម្រោងកម្រិតចែកចាយជាក់លាក់ (កម្រិតដែលត្រូវកំណត់ដោយ DOER)*




*EFSB – ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល*